**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**
**អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក**

លេខ:...៥៥៣......ជជគ.សចរ

ថ្ងៃសុក្រ...១០កើត... ខែ.ភទ្របទ. ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី.២៨.. ខែ...សីហា..... ឆ្នាំ២០២០

# សេចក្តីណែនាំ
## ស្តីពី
## ការបិទស្លាកសញ្ញាចាំងពន្លឺលើយានជំនិះធុនធ្ងន់

យោងតាមបទដ្ឋានបច្ចេកទេសរបស់ UNECE-104R ប្រកាសលេខ២៣៤ ប្រក.សក.ជជគ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីបទដ្ឋានត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្នុងគោលបំណងចូលរួមចំណែកក្នុងការបង្ការ ទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ពាក់ព័ន្ធនឹងយានជំនិះធុនធ្ងន់ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក សូមធ្វើការណែនាំអំពីការបិទស្លាកសញ្ញាចាំងពន្លឺលើ(១)រថយន្តដឹកទំនិញធុនធ្ងន់ (២)យានយន្តឧបករណ៍ (៣)រ៉ឺម៉ក និង(៤)សីមីរ៉ឺម៉ក ដែលមានទម្ងន់សរុបអតិបរមាលើសពី៣,៥តោន ដូចខាងក្រោម៖

១. ស្លាកសញ្ញាចាំងពន្លឺបិទនៅលើយានជំនិះ ត្រូវមានពីរពណ៌ «ក្រហម» និង «លឿង» ដែលមានទទឹងមិនតិចជាង៥០មីលីម៉ែត្រ និងកម្រិតចាំងពន្លឺស្របតាមបទដ្ឋានបច្ចេកទេស VC104+ ។

២. ស្លាកសញ្ញាចាំងពន្លឺ «ពណ៌លឿង» ត្រូវបិទនៅផ្នែកសងខាងតាមបណ្តោយយានជំនិះ ដែលមានប្រវែងមិនតិចជាង៨០% នៃប្រវែងបណ្តោយរបស់យានជំនិះ និងបិទនៅគែមខ្ពស់បំផុតតាមទម្រង់យាន ប៉ុន្តែមិនតិចជាង៤០០មីលីម៉ែត្រពីគែម និងមានប្រវែងមិនតិចជាង២៥០មីលីម៉ែត្រ។

៣. ស្លាកសញ្ញាចាំងពន្លឺ «ពណ៌ក្រហម» ត្រូវបិទនៅផ្នែកខាងក្រោយតាមទទឹងយានជំនិះ និងបិទនៅគែមខ្ពស់បំផុតតាមទម្រង់យាន ប៉ុន្តែមិនតិចជាង៤០០មីលីម៉ែត្រពីគែម។

៤. ករណីរថយន្តដឹកទំនិញធុនធ្ងន់ យានយន្តឧបករណ៍ រ៉ឺម៉ក ឬសីមីរ៉ឺម៉ក ដែលមានទម្ងន់សរុបអតិបរមាលើសពី៣,៥តោន មកទទួលសេវាត្រួតពិនិត្យលក្ខណៈបច្ចេកទេស និងមិនមានបិទស្លាកសញ្ញាចាំងពន្លឺ ឬបិទស្លាកសញ្ញាចាំងពន្លឺមិនស្របតាមបទដ្ឋានបច្ចេកទេសខាងលើ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមខ្លឹមសារប្រកាសលេខ១៧០ ប្រក.សក.ជជគ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ និងណែនាំដល់ម្ចាស់យានជំនិះនោះ ឱ្យបិទស្លាកសញ្ញាចាំងពន្លឺបានត្រឹមត្រូវ ដូចមានក្នុងគំនូរអធិប្បាយណែនាំអំពីការបិទស្លាកសញ្ញាចាំងពន្លឺលើយានជំនិះធុនធ្ងន់ដែលភ្ជាប់ជាមួយ។

ទទួលបានសេចក្តីណែនាំនេះ នាយកដ្ឋានដឹកជញ្ជូនផ្លូវគោក មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុមហ៊ុន ខេមបូឌា ម៉ូធ័រវ៉ីហ៊ីឃល អ៊ិនស្ពេកសិន ខមភេនី និងក្រុមហ៊ុន អេចខេ ខាអ៊ិនស្ពេកសិន ខូ.,អិលធីឌី ត្រូវចាត់ចែងអនុវត្តទៅតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព និងដោយមានស្មារតីទទួលខុសត្រូវខ្ពស់។

**កន្លែងទទួល៖**
- ឯកឧត្តមរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការទទួលបន្ទុក
- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ

**អគ្គនាយក**

**ឈុន-ច័ន់**



មហាវិថី ព្រះនរោត្តម, ភ្នំពេញ
ទូរស័ព្ទ-ទូរសារ: (៨៥៥) ២៣ ៤២៦ ៦៤០, (៨៥៥) ២៣ ៤២៧ ៨៦២

# គំនូរអធិប្បាយណែនាំអំពីការបិទស្លាកសញ្ញាចាំងពន្លឺលើយានជំនិះធុនធ្ងន់

## ក. ការបិទស្លាកសញ្ញាចាំងពន្លឺលើរថយន្តដឹកទំនិញ




## ខ. ការបិទស្លាកសញ្ញាចាំងពន្លឺលើរថយន្តស៊ីទែន



## គ. ការបិទស្លាកសញ្ញាចាំងពន្លឺលើរថយន្តដឹករថយន្ត



ឃ. ការបិទស្លាកសញ្ញាចាំងពន្លឺលើរថយន្តលាយបេតុង




ង. ការបិទស្លាកសញ្ញាចាំងពន្លឺលើរថយន្តដឹកសំរាម



ច. ការបិទស្លាកសញ្ញាចាំងពន្លឺលើសីមីរ៉ឺម៉ក

